ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ២០៥/១៧ ជ.ជ.ក.

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែកញ្ញា និងទិសដៅខែតុលា ឆ្នាំ២០១៧

## I. ស្ថានភាពទូទៅ

ក្នុងខែកញ្ញា ឆ្នាំ២០១៧ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានរកឃើញ និងបង្ក្រាបជាបន្តបន្ទាប់គួរឲ្យកត់សម្គាល់។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការ ទប់ស្កាត់ ជាបន្ទាន់ដោយចាប់ផ្តើមកសាងមណ្ឌលសំចតបណ្តោះអាសន្នឲ្យបានឆាប់ តាមច្រកព្រំដែនកម្ពុជា-ថៃ ដើម្បីគ្រប់គ្រងពលករខុសច្បាប់ដែលអាជ្ញាធរ ថៃបានបញ្ជូនមកគ្រប់ពេលវេលា គ្មានការកំណត់ ។

ដោយឡែកស្ថានភាពពលករចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតីដោយមានប្រជាពលរដ្ឋសម្រុកចេញទៅធ្វើការនៅប្រទេសថៃ បច្ចុប្បន្នមានរហូតដល់ជាងមួយលាននាក់ ក្នុងនោះស្ទើរតែ៧០% មិនមានការបញ្ជូនតាមផ្លូវច្បាប់ ដូចកិច្ចព្រមព្រៀងកម្ពុជា-ថៃ ឆ្នាំ២០០៣ បានកំណត់នោះទេ។ ដើម្បីកាត់បន្ថយភាពរងគ្រោះ និងការកេងប្រវ័ញ្ចលើពលករ រាជរដ្ឋាភិបាលកម្ពុជា តែងបានសហការជាមួយរាជរដ្ឋាភិបាលថៃដើម្បីដោះស្រាយ ដោយផ្តល់ភាពស្របច្បាប់ជូនពលករជាបន្តបន្ទាប់។ ទោះបីជាយ៉ាងនេះក្តី ក៏នៅមានពលករប្រមាណជា ៣០ម៉ឺននាក់ទៀត ដែលមិនទាន់មានឯកសារច្បាប់ត្រឹមត្រូវ។ ថ្មីៗនេះ រាជរដ្ឋាភិបាលថៃបានចេញគោលការណ៍ច្បាប់រឹតបន្តឹងចំពោះពលករបរទេសដែលរស់នៅ និងធ្វើការខុសច្បាប់ តែត្រូវបានពន្យារពេលអនុវត្ត និងដាក់យុទ្ធនាការ ១០០ថ្ងៃ ដើម្បីឲ្យផ្តល់ឯកសារផ្លូវច្បាប់ ជាពិសេសលិខិតឆ្លងដែនដល់ពលករខ្មែរ១៦ម៉ឺននាក់ ឲ្យទាន់ពេលវេលា។ ដោយឡែក ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងលេខ១០២៥ សជណ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ ជូនទៅអាជ្ញាធរ ខេត្តជាប់ព្រំដែន និងខេត្តពាក់ព័ន្ធឲ្យទទួលបន្ទុកដោះស្រាយករណីពលករ ដែលត្រូវបានបញ្ជូនត្រឡប់ឲ្យបានល្អប្រសើរ ។ ចំណែកឯក្រសួងការបរទេសក៏បាន ទប់ស្កាត់សភាពការណ៍ឲ្យពលកររក្សាភាពស្ងប់ស្ងាត់ ដើម្បីទុកឱកាសជូនរាជរដ្ឋាភិបាល ផ្តល់សេវាជូនប្រកបដោយប្រសិទ្ធភាពផងដែរ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។

របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានគឺ ៖

- សម្រាប់បណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់) (ក្រុមការពារជនរងគ្រោះ) ចំនួន០២

ដែលបានផ្តល់របាយការណ៍។ ដោយឡែកក្រសួង ស្ថាប័នចំនួន០៤ ដែលជាយន្តការសម្រប សម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីជានាឲ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត មិនទាន់បានផ្ញើរបាយការណ៍។

- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋានរាជធានី-ខេត្តចំនួន**២២** បានផ្តល់របាយការណ៍ ចំណែក០៣ **រាជធានី-ខេត្ត** គឺរាជធានីភ្នំពេញ កំពង់ស្ពឺ និងខេត្តកែប មិនទាន់បានផ្ញើរបាយការណ៍។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែ**កញ្ញា** ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

#### ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

##### ក.១.១-កិច្ចការច្បាប់

❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពុងពិភាក្សារួមមាន៖
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" **(ច្បាប់ជាតិ)**
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ រដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី ។
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**បត្យាប័ន**"រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស រដ្ឋាភិបាលប៉េរូ សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលរុស្ស៊ី និង
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**" ។

##### ក.១.២-លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

##### ក.១.៣-អនុស្សរណៈ

❖ **អនុស្សរណៈកំពុងរៀបចំ**

-**គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**" ។

-**ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International ។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

ក្នុងខែកញ្ញា ឆ្នាំ២០១៧ ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនចំនួន**២០.០៥៥**ក្បាល ជូនពលរដ្ឋខ្មែរដែលរស់នៅជាប់ព្រំដែន ក្នុងនោះប៉ុស្តិ៍ប៉ោយប៉ែតចំនួន**៧.៣២៩**ក្បាល ប៉ុស្តិ៍អូរស្មាច់ចំនួន៨.៩២១ក្បាលប៉ុស្តិ៍ដូងចំនួន៣.០៣៩ក្បាល ប៉ុស្តិ៍ដាំចំនួន៤២៦ក្បាល និងប៉ុស្តិ៍ព្រំចំនួន៣៤០ក្បាល (របាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍) ។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន**៤.៣១៧**លើក ដែលមានអ្នកចូលរួមសរុបចំនួន**២៩០.២៤៣**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ១៩៨.៦៦៨នាក់) កើនឡើង**៩១.៥៧៥**នាក់ ស្មើនឹង**៤៦.០៩%** ក្នុងនោះស្ត្រីមានចំនួន**១៦០.៨០៩**នាក់។ (ឧបសម្ព័ន្ធទី១)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **ខេត្តសៀមរាប៖**
  - មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាពក្នុងខេត្ត អាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក និងអង្គការពាក់ព័ន្ធចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងកម្មវិធីយើងធ្វើបាន ដើម្បីធ្វើការផ្សព្វផ្សាយ ពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយមិនស្របច្បាប់ ជាពិសេស គឺការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលក្នុងខេត្តបានចំនួន០៧លើក។
  - កងកម្លាំងរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុ ចំនួន ០៤លើក។
- **ខេត្តកំពង់ចាម** លោកវរសេនីយ៍ទោ នាយរងការិយាល័យ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិចំនួន០២លើក ៖
  - ក្រោមប្រធានបទ "ការអន្តរាគមន៍ របស់អាជ្ញាធរចំពោះស្ត្រីដែលរងគ្រោះអំពើហិង្សា ការរៀបការជាមួយជនបរទេស"
  - ក្រោមប្រធានបទ "ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ"។
- **ខេត្តបាត់ដំបង** ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ៖
  - ចូលរួមក្នុងកម្មវិធីសន្ទនាមតិនៅក្នុងវិទ្យុជាតិចម្ការចេក ក្រោមប្រធានបទស្ត្រី និងការធ្វើចំណាកស្រុកការងារ។
- **ខេត្តកោះកុង** ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត៖
  - ផ្សព្វផ្សាយកម្មវិធីកិច្ចពិភាក្សា ស្តីពីជម្រើសដោយសុវត្ថិភាពតាមវិទ្យុសាគរកោះកុង ក្រោមប្រធានបទ លទ្ធផលនៃការជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងការរំលោភបំពានផ្លូវភេទ សហការជាមួយអង្គការចាប់ដៃ សរុបចំនួន**២៩**លើក ក្នុងនោះរួមមាន៖

- ការជួញដូរមនុស្ស ចំនួន១០លើក
- ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងដោយប្រថុយប្រថាន ចំនួន១០លើក
- ការរំលោភបំពានផ្លូវភេទលើកុមារ ចំនួន០៩លើក។

- **ខេត្តកំពត** ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទាស្តីពីសុវត្ថិភាពស្វែងរកការងារធ្វើ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តល់សេវាសមស្រប បានចំនួន០៨ស្រុក ។

**ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស**

**ខ.៤.១-វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ**

កងកម្លាំងនគរបាល វរៈការពារព្រំដែនគោក និងនគរបាលប៉ុស្តិ៍ តាមបណ្តាច្រករបៀងនៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដោយមិនស្របច្បាប់ ឬតាមរយៈមេខ្យល់ ។ ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យារួចហើយ កម្លាំងជំនាញបានណែនាំឲ្យពួកគាត់វិលទៅរកលំនៅដ្ឋានវិញ មានដូចតារាងខាងក្រោម ៖

*តារាងសកម្មភាពបង្ការ និងទប់ស្កាត់*

| ល.រ | លេខាធិការដ្ឋាន គ.ខ.ប.ជ | សកម្មភាពទប់ស្កាត់ | ចំនួនលើក | ចំនួនរួម | ស្រី | អនីតិជន |
|---|---|---|---|---|---|---|
| ១ | **ខេត្តបន្ទាយមានជ័យ** | - កម្លាំងការិយាល័យជំនាញ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងនគរបាលវរៈសេនាតូចការពារព្រំដែនគោក៩១១ និងកម្លាំងអធិការដ្ឋាននគរបាលស្រុកអូរជ្រៅ បានទប់ស្កាត់ពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ ចំណុចតាមព្រំដែនកម្ពុជា-ថៃ (ភូមិសិលាខ្មែរ, ជោគជ័យ ព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ) ។ | ០១ | ១១ | ០៥ | |
| ២ | **ខេត្តព្រះវិហារ** | - ស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការបង្ការ ទប់ស្កាត់ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ០១ | ២៨ | | |
| | | *សរុប* | *០២* | *៣៩* | *០៥* | |

**ខ.៤.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖**

ក្នុងខែកញ្ញា ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុត្តន៍ច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្រង់ស្ថិតិ ទិន្នន័យ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងស្ត្រី-បុរសធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**៤១៤**គោលដៅ មានមនុស្សចំនួន**១.៩១២**នាក់ (ស្រី**១.៥២៥**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មាន៖** (តាកែវ ព្រះវិហារ កណ្តាល កំពង់ឆ្នាំង កែប កំពត កំពង់ចាម មណ្ឌលគិរី ស្ទឹងត្រែង និងស្វាយរៀង)។

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន២០លើក ក្នុងនោះខេត្តដែលអនុវត្តមាន៖ ស្វាយរៀង ព្រៃវែង និងពោធិ៍សាត់។

## ខ.៥.គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

### ខ.៥.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- ***បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក***

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើងជាក់ស្តែងក្នុងខែកញ្ញា ឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែកញ្ញា***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| កញ្ញា | ៣១៧.១៨២ | ១៤២.២៥៤ | ៩.០៧៤ | ៣.៤២១ | ១៧៥.៤៩៧ | ៨៥.៣៣២ | ១.១៨១ | ៥៥០ | ១៤១.៦៨៥ | ៥៦.៩២២ | ៧.៨៩៣ | ២.៨៦៧ | ថយចុះ ១០.៤៥៦ |

### ខ.៥.២ ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** របាយការណ៍ខែកញ្ញា ឆ្នាំ២០១៧ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញមានចំនួន**១៧៧**លើក មនុស្សចំនួន**៣.៧៨១**នាក់ (ស្រី**១.២៣៤**នាក់ និងកុមារ**៣៦៥**នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញចំនួន៤០លើក មនុស្សចំនួន**១០៥**នាក់ (ស្រី**៥៤**នាក់) និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជាថៃចំនួន**១៣៤**លើក មនុស្សចំនួន**៣.៦៧០**នាក់ (ស្រី**១.២២៨**នាក់ និងកុមារ**៣៦៥**នាក់) និងប៉ុស្តិ៍នគរបាលច្រកអន្តរជាតិបាវិតចំនួន**០៣**លើក មនុស្សចំនួន**០៦**នាក់(ស្រី)។
- ក្រុមអនុវត្តន៍ច្បាប់រាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន**១៩៨**នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ ហើយថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៨០ជើង/រថយន្ត ដែលមានមនុស្សចំនួន**៣.៣៦០**នាក់ (ស្រី**១.០៨៨**នាក់) ក្នុងនោះកុមារ**៣៧៦**នាក់ (កុមារី**១៥៩**នាក់) បើប្រៀបធៀបនឹងខែមុនពលរដ្ឋខ្មែរមានចំនួនតែ**៤.៧២៨**នាក់ (ថយចុះ**១.៣៦៨**នាក់) ស្មើនឹង**២៩.៩៣%**។ ក្រោយពីធ្វើការសម្ភាសរួច បានឲ្យយើងដឹងថា៖
  - ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតចំនួន**៩៥៦**នាក់ តាមច្រករបៀងមាន**២.៤០៤**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**១.៣៩០**នាក់ និងតាមគេនាំមាន**១.៩៧០**នាក់។

### ខ.៥.៣ ការតាមដានស៊ើបអង្កេត និងការអនុវត្តនីតិវិធីបញ្ជូនជនបរទេសខុសច្បាប់

**យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញជនបរទេសដែលមកធ្វើការនៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ និងត្រូវបញ្ជូនចេញ:

១.លួចឆ្លងដែនស្នាក់នៅធ្វើការខុសច្បាប់ និងគ្មានលិខិតឆ្លងដែន:ចំនួន២៩លើក មនុស្សចំនួន៧៥នាក់ មាន១០ សញ្ជាតិ ក្នុងនោះ៖ វៀតណាម៤៥នាក់ កូរ៉េខាងត្បូង០២នាក់ នីហ្សេរីយ៉ា១៣នាក់ ឥណ្ឌា០២នាក់ អង់គ្លេស០២នាក់ អាមេរិក០២នាក់ កូឡុំប៊ី០១នាក់ ចិនដីគោក០៦នាក់ កាមេរ៉ូន ០១នាក់និងកូឌីវ័រ០១នាក់មុននឹងបញ្ជូនចេញទៅប្រទេសដើមវិញ ត្រូវបានបោះត្រាហាមចូលប្រទេសកម្ពុជាលើលិខិតឆ្លងដែន។

២.តាមការត្រួតពិនិត្យរបស់ក្រុមចម្រុះអធិការកិច្ចហត្ថពលកម្ម បានរកឃើញចំនួន៨១ក្រុមហ៊ុន ដែលមានពលករគ្មានប័ណ្ណការងារ ចំនួន១១៩នាក់ និងបានផាកពិន័យដល់ពលករម្នាក់ៗ ។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន៩១គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងនារីខ្មែរដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ (រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន១៦/១៨ករណី (បើប្រៀបធៀបនឹងខែមុនថយចុះ០២ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន២៣នាក់ (ស្រី០៧នាក់) យើងបានសង្គ្រោះជនរងគ្រោះចំនួន៣៤នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ០៩នាក់ អាយុពី១៥-១៧ឆ្នាំ០៦នាក់ និងអាយុ១៨ឆ្នាំឡើង១៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១៨នាក់ អង្គការ០១នាក់ និងគ្រួសារចំនួន១៥នាក់)។

**១. ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០៦/០៥ករណី (កើនឡើង០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១១នាក់ (ស្រី០៥នាក់) ជនរងគ្រោះចំនួន១៧នាក់ អាយុក្រោម១៥ឆ្នាំ០១នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង១៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៩នាក់ និងគ្រួសារ០៨នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ១ | ១ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ២ | ៦ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៣ | ៤ | |
| *សរុប* | *០៦ ករណី* | *១១ នាក់* | |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន១០/១៣ករណី (ថយចុះ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ (ស្រី០២នាក់) ជនរងគ្រោះចំនួន១៧នាក់ អាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង០៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៩នាក់ អង្គការ០១នាក់ និងគ្រួសារ០៧នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

Putha

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ញាកម្មទាក់ទងនឹងពេស្យាចារកុមារ<br>-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ<br>-អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ២<br>៣<br>៥ | ២<br>៥<br>៥ | |
| *សរុប* | *១០ ករណី* | *១២ នាក់* | |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និង ជនសង្ស័យ

- យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែរតាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស ដែលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន ៦៩នាក់ (ស្រី២៨នាក់) មកពី ៖

| | | |
|---|---|---|
| - ប្រទេសម៉ាឡេស៊ី | ចំនួន៤៤នាក់ | (ស្រី២១នាក់) |
| - ប្រទេសវៀតណាម | ចំនួន ០២នាក់ | (ស្រី០២នាក់) |
| - ប្រទេសចិន | ចំនួន ០៤នាក់ | (ស្រី០៤នាក់) |
| - ប្រទេសសឹង្ហបូរី | ចំនួន ០១នាក់ | (ស្រី០១នាក់) |
| - ប្រទេសសូម៉ាលី | ចំនួន ១៨នាក់ | |

- យោងស្ថិតិ **អគ្គស្នងការដ្ឋាននគរបាលជាតិ** (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលកររងគ្រោះចំនួន៣៦នាក់ (ស្រី១១នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី១០នាក់ (ស្រី ០៣នាក់) សូម៉ាលី១៨នាក់ ចិន០៧នាក់(ស្រី) និងប្រទេសវៀតណាម០១នាក់(ស្រី)តាមការសម្ភាសន៍ជនរងគ្រោះទៅតាមរយៈមេខ្យល់ទាំងអស់។

### ឃ.២-ការទទួលជនសង្ស័យរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនធើនេសិនណល បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស មាតុភូមិនិវត្ត និងនីរទេសពីប្រទេសនានា សរុបចំនួន៥៣នាក់ (ស្រី១៦នាក់) កុមារ១០នាក់ (កុមារី០៨នាក់) មានដូចជាៈ ប្រទេសម៉ាឡេស៊ី១២នាក់(ស្រី០៦នាក់), សូម៉ាលី១៨នាក់. ថៃ១៦នាក់(ស្រី០៤នាក់) កុមារ១០នាក់ (កុមារី០៨នាក់),ចិន០៥នាក់(ស្រី).វៀតណាម០១នាក់(ស្រី) និងប្រទេសអារ៉ាប់ប៊ីសាអូឌីត០១នាក់។

### ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនធើនេសិនណល បានសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍វិញចំនួន១០នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្ដុះបណ្ដាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល បានចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន១០៤នាក់ ក្នុងនោះមានស្ត្រី៦៤នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិកគ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **ខេត្តកោះកុង** ក្រុមការងារស្រុកស្រែអំបិល បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ០១ | ៤៥ | ២៥ |
| ២ | **មន្ទីរសង្គមកិច្ចខេត្តស្ទឹងត្រែង** សហការជាមួយអង្គការសុខមាលភាពសង្គម និងសាម៉ាក់តាន់កិស បានបើកវគ្គបណ្តុះបណ្តាល ស្តីពីគន្លឹះទាំង៧ នៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់មន្ត្រីសង្គមកិច្ច អង្គការពាក់ព័ន្ធ និងសមាជិក គ.ក.ន.ក ថ្នាក់ឃុំ។ | ០១ | ៥៩ | ៣៩ |
| *សរុប* | | *០២វគ្គ* | *១០៤ នាក់* | *៦៤ នាក់* |

**១.២-កិច្ចប្រជុំការងារដឹកនាំសម្របសម្រួល៖**

ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១០លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០៧លើក និងលេខាធិការដ្ឋាន រាជធានី-ខេត្តចំនួន២១លើក សរុបកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេសសរុប៣៨លើក មានអ្នកចូលរួមសរុប៨០១នាក់ ស្រី១៧៤នាក់។ (ឧបសម្ព័ន្ធទី២)

## ២. ក្រៅប្រទេស

### ២.១.ការចូលរួមបណ្តុះបណ្តាល

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់០១រូប ដើម្បីចូលរួមវគ្គបណ្តុះ បណ្តាល ស្តីពីកិច្ចសហប្រតិបត្តិការព្រំដែនអាស៊ានសម្រាប់គ្រប់គ្រង នៅប្រទេសសិង្ហបុរី ។**

### ២.២.ការចូលរួមសិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានចាត់បញ្ជូនតំណាងក្រសួង៖
  - ទៅចូលរួមសិក្ខាសាលា ស្តីពី "**The Regulation and Manegement of Marriage to de Hosted**" នៅទីក្រុង ប៉េកាំង ប្រទេសចិន។
  - ទៅចូលរួមសិក្ខាសាលាបឋម ថ្នាក់តំបន់ដើម្បីរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការជ្រើសរើសពលករ នៅទីក្រុងបាងកក ប្រទេសថៃ។

### ២.៣.ការចូលរួមកិច្ចប្រជុំ

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** បានចាត់អនុប្រធានក្រុមជំនួយកិច្ចការងារទេសន្តប្រវេសន៍ និងមានតំណាងក្រសួងទៅចូលរួមប្រជុំតុមូលថ្នាក់តំបន់ស្តីពី "**Ruducing Migrant Vulnerabifity in Times of Crisis**" នៅទីក្រុងម៉ានីល ប្រទេសភីលីពីន។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង ។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថមពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស ។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬ

អង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ ។

### គ.សំណូមពរ

- គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន ។
- វគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន ។
- ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច ។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្ម ក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន នោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាជាមិនខាន ។

## V. ទិសដៅខែតុលា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។
៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត ។
៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌ ។
៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត ។
៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។
៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួងស្ថាប័នអង្គការដៃគូក្នុងស្រុកនិងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។
៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។
១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ ។
១១. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ) ។
១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។
១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។
១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល ។
១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជា**អនុព័ន្ធការងារ** ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម ។
១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពី

ប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែកញ្ញា ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 705 លើក | 42,530 នាក់ | 21,561 នាក់ |
| 2 | ខេត្តសៀមរាប | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 647 លើក | 33,773 នាក់ | 19,500 នាក់ |
| 3 | កំពត | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្នុងសហមគន៍ នៃស្រុកទាំង០៨ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 2 លើក | 132 នាក់ | 79 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅស្រុកបន្ទាយមាស កំពង់ត្រឡាច និងស្រុក ទឹកឈូ ។ | | 6 លើក | 194 នាក់ | 93 នាក់ |
| 4 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក។ | ស្នងការដ្ឋាននគរបាលខេត្ត | 19 លើក | 848 នាក់ | 314 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត មន្ទីរកិច្ចការនារីខេត្ត | 35 លើក | 2,850 នាក់ | 1,255 នាក់ |
| 5 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ និងស្រុកបាកាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 40 លើក | 4,722 នាក់ | 2,757 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ ស្រុកភ្នំក្រវាញ និងស្រុកបាកាន ស្រុកវាលវែង។ | ស្នងការដ្ឋាននគរបាលខេត្ត | 402 លើក | 76,595 នាក់ | 47,371 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 949 លើក | 54,352 នាក់ | 27,238 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 410 លើក | 14,639 នាក់ | 7,700 នាក់ |
| 7 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយ ស្តីពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ កិច្ចការពារជនរងគ្រោះ ការជួញដូរមនុស្ស វិធី សាស្ត្រចំណាកស្រុកដោយសុវត្ថិភាព ការរំលោភបំពានផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងមន្ត្រីរាជការ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 1 លើក | 251 នាក់ | 142 នាក់ |
| 8 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 394 លើក | 14,709 នាក់ | 8,799 នាក់ |
| 9 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពាន និង ការធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋ។ | ក្រុមការងារមន្ទីរសង្គមកិច្ចខេត្ត | 7 លើក | 210 នាក់ | 126 នាក់ |
| 10 | ខេត្តកំពង់ចាម | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 146 លើក | 6,340 នាក់ | 2,690 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត<br>ស្នងការដ្ឋាននគរបាលខេត្ត | 262 លើក | 19,006 នាក់ | 9,304 នាក់ |
| 11 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 11 លើក | 478 នាក់ | 229 នាក់ |
| 12 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 244 លើក | 11,141 នាក់ | 6,158 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត<br>មន្ទីរកិច្ចការនារីខេត្ត | 20 លើក | 5,699 នាក់ | 4,344 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 13 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 7 លើក | 857 នាក់ | 691 នាក់ |
| 14 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 9 លើក | 860 នាក់ | 421 នាក់ |
| 15 | ខេត្តព្រះសីហនុ | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 57 នាក់ | 37 នាក់ |

សកម្មភាពសរុបចំនួន: 4,317 លើក

មនុស្សសរុបចំនួន: 290,243 នាក់

ស្រីសរុបចំនួន : 160,809 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៣៨លើក) មនុស្សចំនួន៨០១នាក់ (ស្រី១៧៤នាក់)

| **ស្ថាប័នសម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន១០លើក អ្នកចូលរួមសរុបចំនួន៤៣នាក់ (ស្រី០៨នាក់)<br>❖ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញជួបពិភាក្សាការងារជាមួយលោកស្រី Meloney Lindberg ប្រធានមូលនិធីអាស៊ីប្រចាំកម្ពុជាដែលទើបតែងតាំងថ្មី នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គការ IOM កែសម្រួលកម្មវិធី "អំពីកតិកាសញ្ញាជាសាកល ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ស្របច្បាប់ និងប្រក្រតីភាព របស់អង្គការសហប្រជាជាតិ" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាភាពចូលរួមចំនួន១៣នាក់ ស្រី០២នាក់។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង "ស្តីពីការរៀបចំកិច្ចប្រជុំពិភាក្សា (Policy Dialogue) ក្រុមប្រទេសបញ្ជូន (កម្ពុជា ភូមា ឡាវ) ដើម្បីស្វែងរកបញ្ហា និងដំណោះស្រាយរួម នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន៣០នាក់ ស្រី០៦នាក់។<br>- បានអញ្ជើញក្នុងពិធីជួបសំណេះសំណាលសួរសុខទុក្ខបងប្អូននារីខ្មែរ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសកូរ៉េ រៀបចំដោយមូលនិធិស្ត្រីកូរ៉េ នៅសណ្ឋាគារសុខាភ្នំពេញ ។<br>- បានដឹកនាំប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន "អំពីកិច្ចការងារចាំបាច់មួយចំនួនរបស់ គ.ជ.ប.ជ" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- បានអញ្ជើញចូលរួមក្នុង "សន្និសីទអាស៊ីអឺរ៉ុបលើកទី១៤ ស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍ និងលំហូរទេសន្តរប្រវេសន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប។<br>❖ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជោង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសៀវភៅ កញ្ចប់ឧបករណ៍ C4D របស់ IOMX ស្តីពីការប្រាស្រ័យទាក់ទងដើម្បីការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា រៀបចំដោយអង្គការ IOM នៅភោជនីយ៍ដ្ឋានទន្លេបាសាក់២។<br>- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិល នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀងរាល់ថ្ងៃច័ន្ទសសប្តាហ៍និមួយៗ។<br>❖ **ក្រុមការងារជំនួយកិច្ចការងារទាំង៦**<br>- លោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេស គម្រោង AAPTIP កម្ពុជាលើកទី៩ នៅទីស្តីការក្រសួងយុត្តិធម៌។<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង និងលោក ឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួមប្រជុំក្រុមការងារទេសន្តរប្រវេសន៍អន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពលម្អិត ដែលឆ្លើយតបនឹងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពលោកជំទាវ **ស៊ើង សរសុជាតា** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានក្រុមការងារទេសន្តរប្រវេសន៍ នៅទៅស្តីការក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈ។ |

| | |
|---|---|
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | **សម្របសម្រួលចំនួន០៧លើក**<br>- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធីអាបទីប AAPTIP លើកទី០៩។<br>- បានចូលរួមប្រជុំក្រុមការងារទេសន្តរប្រវេសន៍ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពលម្អិតដែលឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨។<br>- បានចូលរួមប្រជុំពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី ក្រុមប្រទេសបញ្ជូនកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា អំពីបញ្ហារួម និងដំណោះស្រាយដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានប្រជុំរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់នាយកដ្ឋាន។<br>- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់លើកទី០៣ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យដំណើរ និងទេសចរណ៍ នៅខេត្តសៀមរាប។ |
| អគ្គនាយកដ្ឋាន អន្តោប្រវេសន៍ | - បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់០១រូប ចូលរួមសិក្ខាសាលា ស្តីពីការយល់ដឹងអំពីអនុសញ្ញាអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ACTIP) និងផែនការសកម្មភាពអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារភ្នំពេញ ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន២១លើក អ្នកចូលរួមសរុបចំនួន៦៨៦នាក់ (ស្រី១៦៦នាក់)** | |
| ខេត្តកណ្តាល | **សម្របសម្រួលចំនួន០៩លើក អ្នកចូលរួមសរុបចំនួន១៧៥នាក់ (ស្រី១២១នាក់)**<br>- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៧ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុក អ្នកចូលរួមចំនួន១៧នាក់ ស្រី០៣នាក់។<br>- ក្រុមការងារថ្នាក់ស្រុកបានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញា អ្នកចូលរួមចំនួន៦២នាក់ ស្រី៣០នាក់ (០៣លើក)។ |
| ខេត្តស្វាយរៀង | - ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក និងការទប់ស្កាត់អំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៥៨នាក់ (០២លើក)។ |
| ខេត្តស្ទឹងត្រែង | - បានចូលរួមប្រជុំផ្សព្វផ្សាយ អំពីតួនាទីភារកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ដើម្បីពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានត្រឹមត្រូវ និងជួយជនរងគ្រោះទាន់ពេលវេលា អ្នកចូលរួមចំនួន៦៨នាក់ ស្រី២០នាក់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| ខេត្តបន្ទាយមានជ័យ | - ចូលរួមវគ្គបណ្តុះបណ្តាលបន្តវគ្គបង្គោល នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។<br>- ចូលរួមប្រជុំពិគ្រោះយោបល់ គ.ក.ស.ក ប្រចាំខែ នៅសាលាខេត្តបន្ទាយមានជ័យ។ |
| ខេត្តបាត់ដំបង | - ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ការងារទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងរៀបចំផែនការជាអាទិភាព ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយឯក យឹម វិរៈ អគ្គលេខាធិការរង គ.ជ.ប.ជ នៅស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានរៀបចំកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយការជ្រើសរើសពលករទេសន្តរប្រវេសន៍ ឲ្យស្របតាមនីតិវិធីច្បាប់ នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត អ្នកចូលរួមចំនួន១៩នាក់ ស្រី០៨នាក់។<br>- បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាឆ្លុះបញ្ចាំង បទពិសោធន៍រួមគ្នាដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព និងការជួញដូរមនុស្ស ដែល |

| | |
|---|---|
| | មានអ្នកចូលរួមពីខេត្តគោលដៅចំនួន០៣ គឺខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្ត បាត់ដំបង មានអ្នកចូលរួមចំនួន**១១៥**នាក់។ |
| **ខេត្តកំពង់ចាម** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយទេសន្តរប្រវេសន៍ (អភិបាលកិច្ច ទេសន្តរប្រវេសន៍ការងារ)។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ ក្នុងរឿងក្តីស៊ើបអង្កេតពីការជួញដូរមនុស្ស នៅខេត្តក្រចេះ។<br>- បានចូលរួមប្រជុំផ្សព្វផ្សាយស្តីពីការកិច្ចសហកាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម អ្នកចូលរួមចំនួន១៣៥នាក់។ |
| **ខេត្តរតនគិរី** | - បានរៀបចំកិច្ចប្រជុំ ស្តីពីផែនការឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន៣៥នាក់ ស្រី១៧នាក់។ |